# ការសម្ភាសរបស់បងស្រី ក្រាញ់ សាមាន

កៈ អ្នកសម្ភាសឈ្មោះ ម៉េត អេងសួរ ខៈ អ្នកត្រូវបានគេសម្ភាស ក្រាញ់ សាមាន

## សង្ខេបរបស់បងស្រី ក្រាញ់ សាមាន

បងស្រី ក្រាញ់ សាមាន មានអាយុ ៨៣ឆ្នាំ ដែលបងស្រីមានកន្លែងកំណើតនៅ ភូមិឈើទាល ស្រុតក្រោម ឃុំរំចេក ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ បងស្រីមានស្វាមីឈ្មោះ គាន ស្រ៊ាន ប៉ុន្តែ មកដល់បច្ចុប្បន្នពួកគាត់បានលែងលះគ្នាហើយ ប៉ុន្តែចំណងអាពាហ៍ពិពាហ៍របស់ពួកគាត់បាន បន្សល់ទុកនៅកូនប្រុស ២នាក់ឈ្មោះ ស្រ៊ាន គឹម ស្រេង និង ស្រ៊ាន គឹមស្រង់ ។ បងស្រីមាន ឪពុកឈ្មោះ សាយ ក្រាញ់ និងម្តាយឈ្មោះ ប៉ុល រិន ។ បងស្រីមានបងប្អូនប្រុសស្រីចំនួន៦នាក់។

កៈ ជាដំបូងញ៉ុមសូមថ្លែងអំណរគុណដល់បងស្រី ដែលអោយញ៉ុមសម្ភាសបងស្រី។ នៅក្នុងថ្ងៃនេះ ចំពោះការសម្ភាសនេះគឺធ្វើឡើងដោយសកលវិទ្យាល័យមួយនៅ សហរដ្ឋអាមេរិច ដែលមានឈ្មោះ ថា BYU ដែលសកលវិទ្យាល័យមានបំណងចង់ចងក្រងពង្សប្រវត្តិប្រជាជនខ្មែរទុកអោយ កូនចៅ ជំនាន់ក្រោយបានដឹង ។ អញ្ចឹងញ៉ុមអាចយកការសម្ភាសបងស្រីហើយនិង ញ៉ុមដាក់ចូលទៅក្នុងវេប សាយរបស់សាលាដែលមានឈ្មោះថា WWW.cambodianoralhistories.byu.edu បានអត់បងស្រី ?

ខៈ បាន!

កៈ ហ្នឹងហើយ! អរគុណច្រើនបងស្រី អញ្ចឹងចំពោះការសម្ភាសរបស់យើងថ្ងៃហ្នឹងគឺធ្វើឡើងនៅថ្ងៃ ទី១៩ ខែមេសា ឆ្នាំ២០១៨ ។ ហើយធ្វើឡើងនៅ ខេត្តកំពង់ចាម ស្រុកកំពុងសៀម ខេត្តកំពង់ចាម។ ហ្នឹងហើយ ភូមិឈើទាលស្រុតលើ ឃុំរំចេក ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ហ្នឹងហ៊ីយែ! ច្រលំ ត្រលប់ត្រលិន! (សើច) ។ សំនួរជាដំបូងគឺញ៉ុមចង់សួរបងស្រីថាតើបងស្រីមានឈ្មោះអីគេដែរ ?

ខៈ ឈ្មោះ ក្រាញ់ សាមាន ។

កៈ បងស្រីមានឈ្មោះហៅក្រៅអត់ ?

ខៈ មាន! មានក្រៅឈ្មោះ មានៗ ។

កៈ គេហៅអញ្ចឹងណ៎បង ? ចុះបងមានអាយុប៉ុន្មានហើយ ?

ខៈ ៤៣!

កៈ ៤៣ឆ្នាំ! បើសិនជាកើតអឺ... ៤៣ឆ្នាំបើសិនជាឆ្នាំខ្មែរឆ្នាំអីគេ ?

ខៈ ឆ្នាំហ្នឹងហ្ន៎ ?

កៈ ចាស! ឆ្នាំរបស់បងស្រីហ្នឹង។

ខៈ ឆ្នាំ ថោះ។

កៈ ឆ្នាំ ថោះ! ត្រូវជាសត្វអីគេ ?

ខៈ សត្វទន្សាយ ។

កៈ អ៎! ចុះបងស្រីមានទីកន្លែងកំណើតនៅណាទៅ ?

ខៈ នៅខាងឈើទាលស្រុតក្រោម ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

កៈ នៅខេត្តកំពង់ចាមណ៎ ? ចុះបងស្រីមានបងប្អូនប៉ុន្មាននាក់ដែរ ?

ខៈ មានបងប្អូន៦នាក់ ។

កៈ អាចរៀបរាប់ឈ្មោះរបស់ពួកគាត់បានអត់ ?

ខៈ បាន! ឈ្មោះបងម៉េត ចែមឿន ចែមៃ បងម៉ុង ហើយរូបខ្ញុំឈ្មោះមាន ហើយប្អូនគឿន ។

កៈ អញ្ចឹងបងស្រីជាកូនទីប៉ុន្មាននៅក្នុងគ្រួសារ ?

ខៈ ទី៥! កូនទី៥ ។

កៈ បងប្អូនរបស់បងស្រីមាន ៦នាក់។
អញ្ចឹងកាលពីតូចបងមានចងចាំសាច់រឿងអីខ្លះជាមួយពួក គាត់អត់ ?

ខៈ មិនសូវចងចាំប៉ុន្មានទេ។ (សើច)

កៈ ដូចជាអនុស្សាវរីយ៍រត់លេង ឬក៏រកស៊ីអីជាមួយគ្នាលក់អីជាមួយគ្នាអញ្ចឹងហាំ ?

ខៈ ហ្នឹងហើយរកស៊ីបន្តិចបន្តួចហ្នឹងហាំ។ លក់ដូរតិចតួច  ការងារតិចតួចហ្នឹងណាំ ។

កៈ ចុះមានឈ្លោះគ្នាឈ្លោះអីអត់ ? ចងចាំហ្មៅអាកន្លែងហ្នឹង ?

ខៈ អ៊ឹម! ឈ្លោះដែលតិចតួច (សើច) ជាមួយប្អូនអីអញ្ចឹងហាំ។
ឈ្លោះជាមួយប្អូនអីអញ្ចឹងទៅណាំ ។

កៈ ចុះកាលនៅតូចៗហ្នឹង បងស្រីចូលចិត្តលេងអីជាមួយពួកគាត់ ?

ខៈ រត់លេងជាមួយគាត់ដែរ។ រត់លេងពីក្មេងចង់សប្បាយហាំ។ (សើច)

កៈ អញ្ចឹងតើបងប្អូនរបស់បងឥឡូវហ្នឹងពួកគាត់រស់នៅណាខ្លះ ?

ខៈ នៅស្រុកភូមិទៅដូចជានៅ ហាន់ជ័យ ឈើទាលស្រុតលើ ទាលស្រុតក្រោម ហ្នឹង។
ទាំងអស់គ្នា មានក្រុមគ្រួសារនៅខេត្ត កំពង់ចាមហ្នឹង ទាំងអស់គ្នាហ្នឹង។

កៈ គាត់នៅជុំគ្នាទាំងអស់គ្នាណំ ?

ខៈ ហ្នឹងហើយ។ នៅទាំងអស់គ្នា នៅជុំគ្នា។

កៈ អត់មានពីណាគេបាក់បែកអីណាហីបង ?

ខៈ អត់ទេ! អត់មានទេ។

កៈ អញ្ចឹងចូលដល់សំនួរបន្ទាប់ តើបងស្រីមានម្ដាយឈ្មោះអ្វីដែរ ?

ខៈ ឈ្មោះ រិន! សាយ រិន ។

កៈ ចុះលោកឪពុកវិញ ?

ខៈ លោកឪពុកអឺ! មិនមែន។ លោកម្ដាយឈ្មោះ ប៉ុល រិន លោកឪពុកឈ្មោះ សាយ
ក្រាញ់។

កៈ ច្រលំគ្រូកូល! ចុះពួកគាត់ទាំងពីរមកទល់ឥឡូវហ្នឹងគាត់មានអាយុប៉ុន្មានហើយ ?

ខៈ ហ៊ឹម! តែគាត់ស្លាប់ហើយ។

កៈ អ៎! គាត់ស្លាប់អស់ហើយណំ ?

ខ៖ ហ្នឹងហើយ។

ក៖ ចុះបើ... បើសិនជាស្មានបហ្វូមកដល់ឥឡូវគាត់អាយុប៉ុន្មានហើយ ?

ខ៖ អឺ! បើពុកប្រហែលជាអាយុជិត ៩០ ហើយ ៨៥ អីហើយ។ បើម្ដាយអាយុប្រហែលត្រឹម ៨០ ទេមក ដល់ឥឡូវហ៎! ប៉ុនគាត់ខូចតាំងពីអាយុ ៧២ ម្ល៉េះ ។

ក៖ តើបងស្រីមានចាំថ្ងៃ ខែ ឆ្នាំ កំណើតគាត់អត់ ?

ខ៖ អត់ចាំទេ។

ក៖ ទាំងម្ដាយទាំងឪពុក ?

ខ៖ ហ្នឹងហើយ។ អត់ចាំទាំង២នាក់ទាំងម៉ែទាំងពុកហ្នឹង។

ក៖ ចុះដឹងពីកន្លែងកំណើតគាត់អត់ចឹង ?

ខ៖ ដឹងគាត់... គាត់នៅខេត្ត កំពង់ចាម ទាំងអស់គ្នាពុកនៅខាងកោះម៉ែនៅខាង ឈើទាលស្រុត ក្រោម ។

ក៖ អាចរៀបរាប់ពីភូមិ ឃុំ របស់គាត់បានអត់ ?

ខ៖ អឺ...ពុកគាត់នៅភូមិ វត្តព្រះអង្គខ្មៅ។ ម៉ែនៅភូមិ រំចេក ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

ក៖ អ៎! នៅកំពង់ចាម ទាំងអស់គ្នាណ៎ ?

ខ៖ ចាស!

ក៖ កាលដែលពួកគាត់នៅរស់ហ្នឹង តើពួកគាត់ប្រកបមុខរបរអីខ្លះចិញ្ចឹមជីវិត ?

ខ៖ កសិករ!

ក៖ ជាកសិករទាំង២នាក់ណ៎ ?

ខ៖ ហ្នឹងហើយ។

ក៖ តើចំពោះលោកឪពុករបស់បងវិញ តើគាត់ជាមនុស្សបែបណាដែរ ?

ខ៖ ស្លូតត្រង់ហ្វ៎ើ។

កៈ ចុះអ្នកម្ដាយ?

ខៈ អ្នកម្ដាយក៏ស្លូតត្រង់ដែរ។

កៈ ចុះអ្នកម្ដាយគាត់ចិញ្ចឹម... មុខមាន... មានមុខរបរអីខ្លះចិញ្ចឹមជីវិត ?

ខៈ ហ៊ឹម! កសិករម៉ងហាំ។

កៈ អ៎! ដូចគ្នាណ៎ ?

ខៈ ដូចគ្នា។

កៈ កាលដែលពួកគាត់នៅរស់
តើបងចងចាំសាច់រឿងអីខ្លះជាមួយពួកគាត់អនុស្សវរីយ៍អីអញ្ចឹងហាំ ណាំ ?

ខៈ ភ្លេចភ្លាំងអស់ហើយ។ (សើច)

កៈ លើកមួយចំនុចមកភ្លេចម៉េចហ្នែ៎ឪពុកម្ដាយ។

ខៈ ភ្លេចអស់ហើយ។ តែឥឡូវហ្នឹងក៏វាងភ្លេចដែរ។ មិនសូវមានការចងចាំប៉ុន្មានទេ។ (សើច)

កៈ អ៊ូខេ! អញ្ចឹងអត់អីទេបើភ្លេច។
ចុះចំពោះជីដូនជីតារបស់បងស្រីវិញតើបងចងចាំឈ្មោះរបស់ពួក គាត់អត់ ?

ខៈ ចងចាំដែលឈ្មោះត្រកូលខាងតា ក្រាញ់ ឈ្មោះតា យន្ត យាយយន ខាងម្ដាយម៉ែ រិន នេះឈ្មោះ តាយន្ត យាយផន យាយផន អ! ខាងឪពុក តាយន្ត យាយផន ខាងម្ដាយ តានយន្ត យាយយន ។

កៈ តើបងចងចាំ ថ្ងៃ ខែ ឆ្នាំ កំណើតដែលគាត់កើតអត់ ?

ខៈ អត់! អត់ចងចាំផង។ មិនសូវទាន់ផង (សើច) គាត់ចាស់ឯងនៅក្មេង ។

កៈ ចុះនៅពេលដែលពួកគាត់ .... ពួកគាត់អនិច្ចកម្មអស់ហើយមែនអត់ ?

ខៈ អស់ហើយ! អស់ទាំង៤ហ្នឹងហើយ អេ៎!
ទាំង៦ហើយទាំងយាយតាទាំងឪពុកទាំងម្ដាយទាំងអស់ ហ្នឹង ។

កៈ ចុះនៅពេលដែល ... នៅពេលដែលពួកគាត់នៅរស់ តើបងទាន់ជំនាន់គាត់អត់ ?

ខៈ អត់! ជីដូនជីតាអត់ទាន់ទេ ។

កៈ ចំពោះក្រុមគ្រួសាររបស់បង តើបងរស់នៅក្នុងខេត្តកំពង់ចាមហ្នឹងយូរហើយនៅ ?

ខៈ អ់! ទាំងពីតូចម៉េសកំណើត ស្រុកកំណើតនៅហ្នឹងម៉ង។ នៅខេត្តកំពង់ចាមហ្នឹងម៉ង។ នៅឃុំ រំចេកហ្នឹងម៉ងហ្នឹង ។

កៈ អត់ដូរទៅណាសោះម៉ង ?

ខៈ អត់ដូរហ្នេ៎។ (សើច)

កៈ អញ្ចឹងតើបងស្រីមានសាច់ញាតិរស់នៅក្នុងក្រៅប្រទេស ក្រៅពីប្រទេសខ្មែរហាំមានអត់ ?

ខៈ អ៊ឹម! អត់! អត់មានរស់នៅណុងទេ មានតែធ្វើកម្មករគេនៅប្រទេសគេ។ (សើច)

កៈ ហ្នឹងហើយៗ!  គាត់ឈ្មោះអីគេ ?

ខៈ ឈ្មោះក្រាញ់ គឿន ហី ក្រាញ់ ម៉ុង អស់ហើយ។

កៈ គាត់ទៅធ្វើអីដែលនៅណុង?

ខៈ ទៅធ្វើពលករគេហ្នឹងហាំ។

កៈ នៅប្រទេសណាទៅ?

ខៈ ប្រទេស កូរ៉េ។

កៈ អ់! អញ្ចឹងប្រាក់ខែច្រើនហើយនៅប្រទេស កូរ៉េ ហាំ។

ខៈ តិចតួច! តិចតួចហ្នេ៎ស៊ីឈ្នួលគេតិចតួចទេ។

កៈ ទាក់ទងនឹងរឿងផ្ទាល់ខ្លួនរបស់បងវិញ តើបងមានស្វាមីហើយនៅបង?

ខៈ មានហើយ! ប៉ុនបែកគ្នា។ (សើច)

កៈ អាច! អាចសុំសួរឈ្មោះរបស់គាត់ឈ្មោះអីដែរ?

ខ៖ ឈ្មោះប្តីហ្នឹងហ៎! ឈ្មោះ គាន ស្រ៊ាន។

ក៖ ចាស! អាចសុំសួរបន្តិចទៀត ហេតុអីបានបងស្រីបែកគ្នាអញ្ចឹង ?

ខ៖ មើលទៅពិបាកហាស់! យកប្តីពិបាកហាមើលទៅធ្វើបាបពេក ។

ក៖ អ៎! គាត់ធ្វើបាបណ៎? តើបងស្រីរៀបអាពាហ៍ពិពាហ៍ហ្នឹងនៅពេលណាដែរ?

ខ៖ ដូចភ្លេចបាត់ហើយនៀក! (សើច) ឆ្នាំ២០០០ប៉ុន្មាន ១ពាន់ប៉ុន្មានផងភ្លេចហើយ។ ការប្រហែល ១០ឆ្នាំជាងហើយហ្នឹង ។

ក៖ ១០ឆ្នាំជាង ។

ខ៖ ប្រហែល ១៣ឆ្នាំហើយ។ ការប៉ុនបែកគ្នាស្បាក់៧ឆ្នាំហើយ។

ក៖ អ៎! អញ្ចឹងការបានតែ៣ឆ្នាំទេដែលនៅជាមួយគ្នា ?

ខ៖ ហ្នឹងហើយ។ ប្រហែល ៩ហ្នឹង។ ការបានប្រហែល៩ឆ្នាំ ។

ក៖ អញ្ចឹង តើអាពាហ៍ពិពាហ៍របស់បងហ្នឹងរៀបចំឡើងដោយឪពុកម្តាយ ឬក៏បងរៀបចំដោយខ្លួន

ឯង?

ខ៖ ម្តាយ! ម្តាយរៀបចំអោយឪពុកខូចទៅនៅម្តាយ ។

ក៖ អ៎! តើបងទទួលបានជំនួនប៉ុន្មានដែរ?

ខ៖ ម៉ាតិច១លាន ។ (សើច)

ក៖ ២៥០$ ?

ខ៖ ២៥០$ទេ។ ក្របហ្នំ២៥០$ទេអ្នកក្របហ្នំ ។

ក៖ និយាយ១លាន ១លានទៅច្រើន។

ខ៖ ១លានច្រើនជាង (សើច) និយាយ២៥០$តិចហ៎ាបាន ១លានទេបង្គាប់បាន ១លាន ។

ក៖ អត់អីទេ។ ១លានក៏ ១លានអោយតែបានការអ្នកខ្លះសែនទៀតនោះ ចុះធ្វើម៉េចបានជួបគាត់ទៅ ពេលណុងបាន១រៀបការជាមួយគ្នា ?

ខ៖ មានមីងមួយគាត់នាំមកថាឃើញស្មានតែត្រឹមត្រូវដល់ពេលការរួចបានកូន
២នាក់ក៏បែកគ្នាទៅ ទ្រាំមិនបានដែរ ទ្រាំមិនបានទេ ។

ក៖ អញ្ចឹងចូលដល់សំនួរមួយទៀតនិយាយពី ...
តើបងស្រីអាចនិយាយភាសាខ្មែរបានល្អអត់។

ខ៖ ភាសាខ្មែរមិនសូវបានល្អទេព្រោះមិនសូវបានរៀនផង។

ក៖ និយាយប៉ុណ្ណឹងហើយ បានល្អហើយ។

ខ៖ អ៎! អញ្ចឹង ?

ក៖ យើងជាជនជាតិខ្មែរ យើងនិយាយបានល្អហើយ។

ខ៖ ចេះតែខ្មែរប៉ុន្តែ អង់គ្លេស អត់ចេះទេ។

ក៖ អញ្ចឹងភាសាអីផ្សេងអត់ចេះទេណ៎ក្រៅពីខ្មែរ ?

ខ៖ ហ្នឹងហើយ។ ចេះតែខ្មែរ អង់គ្លេស ភាសាអីក៏អត់ចេះដែរ។

ក៖ ចំពោះការសរសេរវិញ តើល្អអត់ភាសាខ្មែរហា៎ ?

ខ៖ អាចសរសេរបានសរសេរភាសាខ្មែរហ្នុ៎។

ក៖ អញ្ចឹងមានន័យថាល្អហើយ អញ្ចឹងតើចំពោះបងស្រីវិ
ញតើបងស្រីរៀនបានថ្នាក់ទីប៉ុន្មានដែរ ?

ខ៖ ទី៨! បានថ្នាក់ទី៨ទេ។

ក៖ ថ្នាក់ទី៨ រៀននៅសាលាណាដែរ?

ខ៖ សាលារំចេក ស្រុកកំពង់សៀម ខេត្តកំពង់ចាមហ្នឹង ។

ក៖ សាលាឈ្មោះ រំចេក ណ៎?

ខ៖ ហ្នឹងហើយ។

ក៖ ចុះបងស្រីកាលនៅរៀនធ្លាប់មានមិត្តភ័ក្តស្និទ្ធស្នាលបំផុតអត់?

ខ៖ អត់ដែលមានមិត្តភ័ក្តទេ។

កៈ ហ៊ឹម! ម៉េចចឹង?

ខៈ អត់ចូលចិត្តរៀនមានមិត្តភ័ក្តផង។

កៈ ចុះបងស្រីធ្លាប់ធ្វើការនៅវាលស្រែអត់ចុះ?

ខៈ ធ្លាប់! អ៎! អាហ្នឹងជំនាញរបស់ខ្ញុំហើយខាងស្រែហ៎ា។ (សើច)
ខាងធ្វើស្រែជំនាញរបស់ខ្ញុំហើយបើ ធ្វើអីផ្សេងខ្ញុំអត់ចេះទេ ។

កៈ ចុះអញ្ចឹងក្រៅពីធ្វើស្រែបងស្រីអត់ធ្លាប់មានមុខរបរអីទៀតទេណ៎ ?

ខៈ អត់មានផង មានតែធ្វើស្រែមួយមុខ។

កៈ ចុះឥឡូវនៅធ្វើស្រែទៀតអញ្ចឹង?

ខៈ ឥឡូវនៅតែធ្វើស្រែអញ្ចឹង។

កៈ ជីវិតរបស់បងស្រីតាំងពីក្មេងរហូតមកដល់ឥឡូវ តើមានការផ្លាស់ប្តូរអីអត់?

ខៈ អត់ផ្លាស់ប្តូរ យ៉ាប់រហូត។ ការងារមានយ៉ាប់រហូតមានដែលទំនេរបានមួយពេលណាទេ
មិនដែល ស្រួលផង ។

កៈ
អត់ដែលស្រួលតិចទៀតកូន...មានកូនដល់ពេលកូនធំទៅស្រួលវិញហើយកូនចិញ្ចឹមវិញ។

ខៈ ដឹងបានចិញ្ចឹមទៅមានអីខ្លាចវាអត់តាមគន្លងធម៌ទៅ វាពិបាកដល់ម៉ែវាទៀត ។

កៈ សន្សំលុយអោយកូនទៅកូរ៉េទៅ។

ខៈ អើ! ដឹងកូនអាចបានទៅអត់ផង។ មិនដឹងមាននិស្ស័យអត់។

កៈ អោយវារៀនបានខ្ពស់ទៅ។

ខៈ រាល់ថ្ងៃប្រឹងអោយរៀនបានថ្នាក់ទី៦ អាធំហ្នំ! បើអាតូចបានថ្នាក់ទី២
មិនទាំងចេះអីបន្តិចផង។

កៈ វានៅតូចពេកអញ្ចឹងហើយ។ ចំពោះម្ហូបអាហារវិញ តើម្ហូបណាដែលបងចូលចិត្តជាងគេ?

ខៈ គ្មានអីក្រៅពីស្លម្ជូរ ប្រហើរ ហ្នំ។

កៈ ចុះបងចេះស្លសម្លទាំងអស់ហ្នឹងអត់?

ខៈ ចេះតើសម្លហ្នឹងចេះ។ បើសម្លអីផ្សេងៗមិនសូវចេះប៉ុន្មានហ្នំ បានតែស្លម្ជូរ ស្លប្រហើរ ស្លកកូ អីចេះ ចៀនអីអញ្ចឹងទៅចេះ ។

កៈ ដល់ពេលចង់ ធ្វើម៉ងទៅណា៎?

ខៈ បើឃ្លានមុខអីចង់សម្លណុងស្លទៅ។

កៈ ចំពោះបទចម្រៀងវិញ តើបងមានចូលចិត្តចម្រៀងណាជាពិសេសអីអត់?

ខៈ អ៊ឹម! ចម្រៀងបទពីដើមចូលចិត្តហើយភ្លេងការចូលចិត្តម៉ង។

កៈ ចុះចេះច្រៀងអត់ចុះ?

ខៈ អត់! អត់ចេះច្រៀងទេ គ្រាន់តែចង់ស្តាប់។

កៈ ចំពោះគ្រួសាររបស់បង
តើមានសមាជិកក្នុងគ្រួសារណាមួយដែលចេះលេងឧករណ៍ភ្លេង តន្ត្រី អីអត់?

ខៈ អត់ចេះផង! អត់មានចេះផង។ កូនអត់មានចេះផង។

កៈ ចុះផ្ទះរបស់បងតាំងពីតូចរហូតមកដល់ឥឡូវហ្នឹង មានលក្ខណៈបែបណា? មានលក្ខណរបៀប ថាផ្លាស់ប្តូរអីអត់?

ខៈ អត់ផ្លាស់ប្តូរទេ នៅដដែល។

កៈ ផ្ទះបែបម៉េចទៅបង?

ខៈ ផ្ទះហ៎ ? ផ្ទះ ផ្លាស់ផ្ទះចាស់មកផ្ទះថ្មីប៉ុនផ្ទះ ....

កៈ ផ្ទះប្រក់ក្បឿង?

ខៈ ប្រក់ក្បឿង។

កៈ អ្នកខ្លះមានផ្ទះ ស្បូវ អ្នកខ្លះមានអីអញ្ចឹងហា៎ណា៎ ដល់ពេលផ្ទះយើងប្រក់ក្បឿង ប្រក់ក្បឿងមក រហូតចឹង។

ខៈ អ៎! ហ្នឹងហើយពីមុនមកផ្ទះម៉ែប្រក់ក្បឿង ដល់មកឥឡូវរុះធ្វើថ្មីធ្វើផ្ទះក្បឿងដដែល។

ក៖ អ៎! អញ្ចឹងបងស្រីមានផ្ទះថ្មីមែនហ្មង់បង?

ខ៖ ហ្នឹងហើយមានផ្ទះថ្មី។

ក៖ អញ្ចឹងមានន័យថាផ្ទះថ្មីហ្នឹងបងអ្នកសាងសង់ខ្លួនឯង?

ខ៖ សាងសង់ខ្លួនឯង។

ក៖ ចុះមានឧបករណ៍អីខ្លះទៅនៅពេលដែលបងសាងសង់ផ្ទះ?

ខ៖ អត់មានអីទេ។ នៅទទេឡើងរបោររហេរគ្មានអីទេ។

ក៖ ឧបករណ៍សាងសង់ផ្ទះ?

ខ៖ អ៎! ឧបករណ៍សាងសង់ផ្ទះម៉េច?

ក៖ ដូចជារនាប។

ខ៖ ហ្វ៎! រនាបហ៎? ហ្នឹងហើយ។ មានរនាប ប្រក់ក្បឿង បាំងជញ្ជាំងក្ដា ប៉ុណ្ណឹង។

ក៖ តើបងមានជំនាញអីខ្លះដែរ ជាជំនាញមួយប្រចាំត្រកូលរបស់បងហ៎
ដែលបងបន្តវេនពីគ្រួសារ មករហូតអញ្ចឹងហ៎ណា៎? មានជំនាញហ្នឹងអត់បង?

ខ៖ ធ្វើស្រែ។

ក៖ អត់ដឹងទេ! ជាជំនាញអីក៏បានដែលបងបានបន្តវេនពីឪពុកម្ដាយបងមកអញ្ចឹងហ៎។

ខ៖ មានតាធ្វើស្រែចម្ការហ្នឹងទេ។

ក៖ អូខេ! អញ្ចឹងធ្វើស្រែចម្ការណា៎? ចំពោះការលំបាកវិញ?
តើការលំបាកអីខ្លះដែលបងលំបាកបំផុត នៅក្នុងជីវិតរបស់បងហ្ន៎?
បងអាចលើកមកបន្តិចបានហ្មង់ តើការលំបាកអីគេដែល គឺពិបាកបំផុត
ម៉ងហ៎តាំងពីដំណើរជីវិតមកដល់ឥឡូវហ៎ ?

ខ៖ អើយ! ជីវិតតាំងពីដឹងក្ដីថ្ងៃណាមកពិបាករហូតហ្នឹង
មិនដែលឃើញស្រួលទេពិបាកណាស់។

ក៖ អាចលើកអាលំបាកបំផុតបន្តិចបានអត់?

ខ៖ ហ៊ឹម! លំបាកណាស់មានតែធ្វើស្រែចម្ការហ្នឹង លីសែងតែឯងហ្នឹង។

ក៖ លីសែងអីគេទៅ?

ខ៖ លីប៉េក្រាមយកទៅដាក់ស្រូវអីអញ្ចឹងទៅណា៎។

ក៖ អត់មានពីណាគេជួយទេលីខ្លួនឯង?

ខ៖ អត់មានពីជួយទេ បើតែឯង លីខ្លួនឯងអីខ្លួនឯងលីទុយយូ
លីអីទៅទុយយូបូមទឹកអញ្ចឹងទៅគ្មាន ពីណាជួយតែឯងហ៎! កូននៅតូចៗអញ្ចឹងហ៎។

ក៖
ចុះបង...បងឆ្លងកាត់វាដោយរបៀបណាទៅដើម្បីអោយផុតពីការលំបាកហ្នឹងអញ្ចឹងហា៎?

ខ៖ ហ៊ឹម! រឿងឆ្លងកាត់ អ៊ឹម!
មិនដឹងថ្ងៃណាឆ្លងកាត់បានស្រួលទេពិបាកឃើញតែពិបាករហូត។

ក៖ អត់ទេចង់និយាយថា ការលំបាកដែលបងលីស្រូវ លីអីអញ្ចឹងលីក្រាម
លីអីទៅស្រែអញ្ចឹងហា៎ ធ្វើម៉េចដើម្បីអោយផុតពីការលំបាកហ្នឹងអញ្ចឹងហា៎ណា៎?

ខ៖ មិនដឹងធ្វើម៉េចអោយផុតទេ បើវានៅតែប៉ុណ្ណឹង។

ក៖ ចំពោះរឿងល្អៗ មិញយើងនិយាយអំពីរឿងពិបាកៗអញ្ចឹង ចំពោះរឿងល្អៗវិញ។
តើពេលវេលា ណាដែលបងគិតថាជាការល្អរបស់បងអញ្ចឹងហា៎ណា៎
ដែលបងគិតថាវាល្អបំផុតសម្រាប់ជីវិតបងហា៎ បងរំភើប ឬក៏អីអញ្ចឹងហា៎?
ដូចឧទាហរណ៍ថា ពេលដែលបងរៀបអាពាហ៍ពិពាហ៍ ឬក៏អីៗអញ្ចឹងហា៎ ណា៎?
មានហ្មេបង?

ខ៖ ហ៊ឹម! ដូចគ្មានល្អទេ បើចាប់ដៃគ្នាមកមិនទាំងល្អផង។

ក៖ អត់ទេ! អញ្ចឹងចុះមុនពេលរៀបអាពាហ៍ពិពាហ៍ តើមានរំភើបអីអត់?

ខ៖ អត់! អត់មានរំភើបទេ។

ក៖ អញ្ចឹងកាលពេលដែលបងនៅក្មេងតើបងសង្ឃឹមចង់ធ្វើអីគេនៅក្នុងចិត្ត
ឧទាហរណ៍ថានៅពេល ដែលបងរៀនហ្នឹ។ បងគិតថាពេលធំឡើងបបងចង់ធ្វើអី ?
សង្ឃឹមក្នុងចិត្តថាចង់ធ្វើអីគេ?

ខ៖ ចង់! និយាយទៅសង្ឃឹមធំឡើងបើសិនជាចេះវិញចង់ធ្វើ តារាចម្រៀង។

ក៖ អូ! អញ្ចឹងមានន័យថាបងចូលចិត្តច្រៀងមែនអត់បង ?

ខ៖ ចង់ច្រៀង ប៉ុន្តែវាអត់ចេះ។

ក៖ ចង់ធ្វើ តារាចម្រៀងទៀត។ អញ្ចឹងបងចង់ធ្វើតារាចម្រៀង ប៉ុន្តែឥឡូវអត់ទាន់ហួសពេលទេបង អាចបង្ហឹកអាចរៀនធ្វើជាតារាចម្រៀងបាន អញ្ចឹងបងចង់ធ្វើអត់?

ខ៖ ចង់ ប៉ុន្តែវាអត់ចេះ វាអត់ចេះម៉ងហ្នឹងហាអក្សរខ្មែរហ្នឹងវា វាមិនសូវប៉ិនធ្វើក្រលិក្រលាក់ហ្នឹងគេ ហ្នឹងណា វាអត់ចេះសោះម៉ងហ្នឹងហា! ប៉ុនគ្រាន់តែចង់ហ្នឹងហា។ (សើច)

ក៖ អត់ទេ និយាយពីចម្រៀងអត់ទាក់ទងជាមួយអក្សរហ្នោ។

ខ៖ បើវា...បើវាអត់ចេះផង បើគិតតែរកអោយកូនស៊ីមិនចង់បានផង ទៅគិតអាចម្រៀងចង់វាចេះ តែចង់ហើយ ។

ក៖ ទាក់ទងជាមួយនឹង គ្រួសាររបស់បងម៉ាតិចទៀត។ មិញ សូមបង្វែរទៅម៉ាតិចទៀតដោយសារ អត់បានសួរមួយសំនួរ ចំពោះបងថាបងរៀបការហើយចុះបងមានបុត្រាបុត្រីអីអត់បង?

ខ៖ មាន២នាក់។

ក៖ គាត់ឈ្មោះអីខ្លះទៅបង?

ខ៖ ឈ្មោះ ស្រ៊ាន គឹមស្រេង មួយ ស្រ៊ាន គឹមស្រង់ មួយ ២។

ក៖ ស្រី...ស្រី ប្រុសបង?

ខ៖ ប្រុសទាំង២។

ក៖ ប្រុសទាំង២អោយលុយគេទាំង២ហើយចឹង?

ខ៖ អោយលុយគេទាំង២ តែម៉ែរកអត់បានផង។

ក៖ តិចទៀតរកបានហើ៎។ ចុះនៅពេលអនាគតបងមានបំណងចង់អោយពួកគាត់រៀនបន្តអោយ កាន់តែខ្ពស់ ឬក៏ចង់អោយគាត់រៀនត្រឹមថ្នាក់ណាឈប់ ឬម៉េចអញ្ចឹងហាណាបង?

ខ៖ ចង់អោយខ្ពស់ ប៉ុន្តែម្តាយមិនសូវមានលុយផងអោយត្រឹមបានថ្នាក់ទី១០ហា៎។

ក៖ ត្រឹមថ្នាក់ទី១០ទាំង២ហ៎បង?

ខ៖ ហ្នឹងហើយ។ បានថ្នាក់ទី១០ ទាំង២ហ្នឹង។

ក៖ ហើយប្រឹងអោយគាត់ធ្វើអីទៀតទៅអញ្ចឹង?

ខ៖ ហុឹម! ចង់អោយធ្វើជាងអីទៅ។

ក៖ អត់ចង់អោយទៅ កូរ៉េ ទៅអីទេណ៎?

ខ៖ ចង់! ប៉ុន្តែ...ប៉ុន្តែបើវាអាជីពណាអោយវាកាន់អាជីពហ្នឹងទៅ
វាចង់ធ្វើអីអោយវាធ្វើណុងទៅ។

ក៖ អញ្ចឹង! ចុះបើក្នុងគោលបំណងរបស់បងវិញ
បើសិនជាបងអាចអោយពួកគាត់រៀនបានខ្ពស់ដល់ សកលវិទ្យាល័យអីអញ្ចឹងហា៎
តើបងចង់អោយគាត់រៀនខាងអីទៅ?

ខ៖ មិនដឹងទេ! មិនដឹងអោយរៀនខាងអីផង។ បើខ្ញុំអត់ចេះផង ហ្នឹងហើយ។
រៀនបានថ្នាក់ទី៤អត់ ដឹងអត់ចេះផង អត់ដឹងថារៀនដល់អីផង។

ក៖ ដឹងតែរៀនអីរៀនទៅអោយតែបានលុយច្រើនអញ្ចឹងមែន?

ខ៖ ហ្នឹងហើយ។ ចង់អោយបានលុយ ចិញ្ចឹមម្តាយវិញម្តាយហា៎ខ្សត់ខ្សោយណាស់។

ក៖ ចុះក្នុងនាមបងជាម្តាយបងចង់អប់រំកូនយ៉ាងម៉េចដើម្បីអោយដូចថា
វាដើរតាមផ្លូវគន្លងធម៌អី អញ្ចឹងហា៎ណ៎ ?

ខ៖ អើយ! អប់រំណាស់រាល់ថ្ងៃហ្នំ ខ្លាចតែទៅមុខទៀតវាតាមគេតាមឯងអញ្ចឹងហា៎ណ៎
រាល់ថ្ងៃចង់ អោយកូនណាស់ អោយតាមផ្លូវល្អ ប៉ុន្តែខ្លាចតែទៅមុខទៀតណ៎
មិនដឹងអាម៉េចទេកូននោះ។

ក៖ ចុះបងសម្លឹងមើលអត្តចរិកគាត់មកដល់ឥឡូវហ្នឹង តើគាត់អាចដើរតាមគន្លងធម៌
ឬក៏គាត់ខូច ឬ ក៏ម៉េច?

ខ៖ រាល់ថ្ងៃហ្នឹងតាមគន្លងធម៌ ប៉ុនខ្លាចតែថ្ងៃមុខទៀតតាមមិត្តភក្តិ ខ្លាចអញ្ចឹង។

កៈ ចុះបងមានវិធានការម៉េចដើម្បីការពាគាត់កុំអោយដើរ
ភ្លើតភ្លើនតាមមិត្តភក្តិអញ្ចឹងហាំណាំ តាម សង្គមអីអញ្ចឹងហាំ?

ខៈ រាល់ថ្ងៃហ្នឹងប្រដៅកូនកុំអោយដើរ។ កុំអោយមានមិត្តភក្តិពិបាកហាំ ដឹងគាត់តាមទេ។
មិត្តភក្តិល្អ ចេះតែ បើមិត្តភក្តិខូចអត់អោយដើរតាមទេបើមិត្តភ័ក្តល្អទេ។

កៈ អញ្ចឹងបើសិនជាបងអាចផ្តាំផ្ញើរទៅកូនចៅជំនាន់ក្រោយរបស់បង
តើបងមានពាក្យពេចន៍អីខ្លះ ដើម្បីអប់រំដល់ពួកគាត់។ ឧទាហរណ៍ថាចង់អោយពួកគាត់ល្អ
កុំអោយដើរតាមគន្លងអាក្រក់ៗ ឬក៏
ចង់អោយគាត់រៀនបានខ្ពស់កុំអោយដូចបងរៀនបានត្រឹងថ្នាក់ទី៤
អត់ចេះអីអញ្ចឹងហាំណាំ?

ខៈ ចង់អោយកូនបានរៀនថ្នាក់ធំ អោយបានតាមគន្លងធមិល្អ
អោយចង់អោយបានធ្វើការងារហ្នឹង ណាំ។

កៈ ធ្វើម៉េចក៏បានអោយតែបានប្រាក់ខែច្រើន។

ខៈ បានប្រាក់ខែច្រើនកាលណាល្អកាលហ្នឹង។

កៈ តែក៏ជាមនុស្សមួយដែលសង្គមទទួលស្គាល់ដែរ។

ខៈ ហ្នឹងហើយ អោយសង្គមគេទទួលស្គាល់។

កៈ ហ្នឹង!
អញ្ចឹងអគុណច្រើនណាបងដែលអនុញ្ញាតអោយញ៉ុមធ្វើការសម្ភាសបងនៅថ្ងៃហ្នឹង។
អរគុណច្រើនបងជម្រាបលាបង។